I - ទីស្ដីការគណៈរដ្ឋមន្ត្រី

១- អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ១៩៩៤

អនុក្រឹត្យលេខ ៣០ អនក្រ

ស្ដីពីការកំណត់ភារកិច្ច និង សមត្ថកិច្ចរបស់

ទេសរដ្ឋមន្ត្រីទទួលបន្ទុក កិច្ចការអធិការកិច្ច

***

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

មាត្រា ១ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអធិការកិច្ច មានសមត្ថកិច្ចជំនួយការជូនរាជរដ្ឋាភិបាលលើការធ្វើអធិការកិច្ចគ្រប់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុងសំខាន់គឺសំដៅពិនិត្យនិងតាមដានការអនុវត្ត រាល់លិខិតបទដ្ឋានដែលរដ្ឋសភាបាន អនុម័ត និងគណៈរដ្ឋមន្ត្រីបានសំរេច និង តំរង់ទិសនូវរាល់ការអនុវត្តកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងការដឹកនាំ និង គ្រប់គ្រងរបស់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុងដោយសហការអោយបានជិតស្និទ្ធ

បំផុតជាមួយជំនាញ អធិការកិច្ច និងថ្នាក់ដឹកនាំ នៅទីកន្លែងដែលត្រូវបំពេញភារកិច្ច ។

មាត្រា ២ :ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអធិការកិច្ចមានតួនាទី និងភារកិច្ចដូចតទៅ ៖

-តាមដាននិងធ្វើវិចារកម្មលើកគំរោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល អំពីគោលការណ៍ទិសដៅដឹកនាំគ្រប់គ្រងពង្រឹងអធិការកិច្ច និងកំណត់ នូវមុខសញ្ញា អាទិភាពក្នុងការកសាងកែលំអច្បាប់ និង បទបញ្ញត្តិផ្សេងៗដែលទាក់ទងទៅ នឹង ការងារអធិការកិច្ចដើម្បីធានាបាន នូវ ប្រសិទ្ធភាពខ្ពស់ក្នុងការងារនេះ ។

-សហការជាមួយក្រសួង និង ស្ថាប័ននានាដើម្បីរៀបចំវិភាគនិងផ្តល់ ឯកសារព្រមទាំងពត៌មានលើបញ្ហា ដែលពាក់ព័ន្ធការងារអធិការកិច្ច ។

-ធ្វើការតាមដានលើការអនុវត្តកម្មវិធី និង គំរោងផ្សេងៗ របស់រាជ រដ្ឋាភិបាល ដោយសហការជាមួយក្រសួង ស្ថាប័នជំនាញនានាដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និង សំរេច ។

-ទទួលភារកិច្ចផ្សេង ៗ ទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

មាត្រា ៣ : ក្នុងករណីពិសេសរាជរដ្ឋាភិបាលចាត់តាំងគណៈកម្មការមួយ ដើម្បី ចុះធ្វើអធិការកិច្ចផ្ទាល់ដល់ទីកន្លែងនិមួយ ៗ ។

មាត្រា ៤ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអធិការកិច្ច អាចមានឧបការី អ្នកជំនាញការ និង ទីប្រឹក្សាបំរើការងារក្នុងលេខាធិការដ្ឋានប្រតិបត្តិមួយ ដើម្បីសំរេចនូវ ភារកិច្ចដូចបានកំណត់ខាងលើ ។

មាត្រា ៥ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអធិការកិច្ច មានសិទ្ធប្រើប្រាស់រចនា សម្ព័ន្ធនិងក្របខ័ណ្ឌមានស្រាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជំនួយក្នុងការងារ។ ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការអធិការកិច្ច មានសិទ្ធប្រើប្រាស់ត្រាដោយឡែក។

មាត្រា ៦ : ថវិកា ចំណាយលើការងាររដ្ឋបាលកិច្ច នៃ រាជរដ្ឋាភិបាលស្ថិតក្នុងថវិកាទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៧ : បទបញ្ញត្តិណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៨ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលបន្ទុកអធិការកិច្ចត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ។

មាត្រា ៩ : អនុក្រឹត្យនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី២
ហត្ថលេខា និងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកក្កដាឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ៦០ អនក្រ
ស្តីពីការរៀបចំនិងចាត់តាំងមុខងារនាយធាហាន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា